**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

---

តុលាការខេត្តកណ្ដាល
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៣៦ អ.ក ចុះថ្ងៃទី ៣០
ខែ មិថុនា ឆ្នាំ ១៩៩៥
ជំនុំជំរះ
លេខ ០៣ ក ចុះថ្ងៃទី ១២
ខែ មករា ឆ្នាំ ១៩៩៦
សាលក្រម
លេខ ០៣ ក ចុះថ្ងៃទី ១២
ខែ មករា ឆ្នាំ ១៩៩៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តកណ្ដាល**

បង្កើតឡើងតាមច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកណ្ដាល នាថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្តកណ្ដាល

សាលក្រមនេះចូលជាស្ថាពរចាប់តាំងពីថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦ ចំពោះឈ្មោះ យ សរ ។
កណ្ដាល.ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦
ក្រឡាបញ្ជី
[redacted]
បានឃើញ
ប្រធានតុលាការខេត្តកណ្ដាល
[redacted]

ដើម្បីជំនុំជំរះជនជាប់ចោទឈ្មោះ **យ សរ** ហៅ **យ** ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា កើតនៅភូមិទះរមាំង ឃុំក្រចម ស្រុកពារាំង ខេត្តព្រៃវែង កំរិតវប្បធម៌ ថ្នាក់ទី ៣ថ្មី សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិបឹងក្រចាប់ជើង ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល របររកស៊ី ធ្វើស្រែ ប្រពន្ធឈ្មោះ **ស សរ** គ្មានកូន ឪពុកឈ្មោះ **យ** (ស) ម្ដាយឈ្មោះ **ប ម** (ស) ទោសពីមុនគ្មាន ត្រូវចាប់ខ្លួននៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

ជាប់ចោទពីបទ : **ចោរកម្ម** ប្រព្រឹត្តនៅភូមិបឹងក្រចាប់ជើង ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥ តាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

តុលាការខេត្តកណ្ដាលសម្រេចតាមដីកាលេខ ៥៤ ដកទម ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ ទទួលលោកស្រី [redacted] នាងឡូ ជាអ្នកការពារឱ្យជនជាប់ចោទឈ្មោះ **យ សរ** ។

ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ **ឡ ម៉ល** ភេទប្រុស អាយុ ៣៩ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិបឹងក្រចាប់ខាងជើង ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ប្ដឹងទាមទារតម្លៃគោរបស់ខ្លួនចំនួនមួយក្បាល តម្លៃ ០៧ជីមាស ។

-តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៨៧ ដកសព/៩៥ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្ដាល ។

-តាមដីកាបញ្ជូនរឿងឱ្យជំនុំជំរះលេខ ២១២ ដជរ/៩៥ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា

ឆ្នាំ ១៩៩៥ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្តកណ្តាល ។

-តាមដីកាចាត់តាំងចៅក្រមលេខ : ២៦៦ ដកច/៩៥ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់តុលាការខេត្តកណ្តាល ។

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ :

កាលពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥ វេលាម៉ោង ២៤:០០ ឈ្មោះ យ សរ ហៅ យ បានចូលលួចគោឈ្មោលមួយក្បាល សំបុរ(ស)ស្នែងវែង ជាគោរបស់ឈ្មោះ ឡ ម៉ល នៅភូមិបឹងក្រចាប់ជើង ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ ពេលលួចគោបានហើយឈ្មោះ យ សរ បានដឹកគោនេះសំដៅទៅទិសខាងត្បូង លុះដល់ចុងស្ពានព្រែកកុងអាន ក្នុងភូមិព្រែកក្រោម ឃុំពុកឫស្សី ក៏ជួបនឹងមនុស្សមិនស្គាល់ឈ្មោះបីនាក់និយាយថា ឈ្មោះ ច ឱ្យមកទទួលគោនេះពីឈ្មោះ យ សរ ឮដូច្នោះឈ្មោះ យ សរ ក៏ប្រគល់គោឱ្យទៅមនុស្សទាំងបីនាក់នោះ ហើយក៏ដើរត្រលប់មកវិញ ។

បានឃើញរបាយការណ៍ស្រាវជ្រាវករណីចោរលួចគោនៅថ្ងៃទី ២៧ ខែ ឧសភា ឆាំ ១៩៩៥ វេលាម៉ោង ២៤:០០នាទី នៅចំណុចភូមិបឹងក្រចាប់ជើង ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល លេខ ១០២/៩៥ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់នគរបាលស្រុកខ្សាច់កណ្តាល ។

## នាពេលសួរនាការ

ជនជាប់ចោទឈ្មោះ យ សរ ហៅ យ បានឆ្លើយថា : កាលពីថ្ងៃខែមិនចាំខ្លួនបានទៅស្រាយយកគោមួយក្បាល ដែលចងនៅក្រោមផ្ទះឈ្មោះ ឡ ម៉ល ។ ពេលស្រាយបានហើយខ្លួនក៏ដឹកគោនេះចេញមកដល់ព្រែក-កុងអាន មានមនុស្សមិនស្គាល់ចំនួនបីនាក់រឺខ្លួន ហើយដឹកយកគោនោះទៅបាត់ទៅ ។ ពេលនោះមនុស្សបីនាក់នោះនិយាយថាឈ្មោះ ច ឱ្យមកទទួលគោពីខ្លួន ហើយខ្លួនបានដេកនៅទីនោះរហូតដល់ព្រឹកឡើង ក៏បានធ្វើដំណើរទៅរស់នៅភូមិព្រែកស្វា ខេត្តព្រៃវែង លុះបានមួយខែក៏ត្រលប់មកផ្ទះវិញ ហើយស្ថាប័នមានសមត្ថកិច្ច ក៏ចាប់ខ្លួនតែម្តង ។ ពីមុនមកខ្លួនធ្លាប់លួចគោឈ្មោះ [redacted] សុខុម ម្តងដែរ តែពេលដឹកយកមកដល់ផ្ទះក៏ដឹកត្រឡប់យកទៅចងទុកនៅកន្លែងដើមវិញ ។

តាមការអានចម្លើយរបស់ឈ្មោះ [redacted] សុខុម ដែលបានឆ្លើយនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ចំពោះមុខនគរបាលស្រុកខ្សាច់កណ្តាលថា : កាលពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៩៥ វេលាម៉ោងប្រហែល ២៣:៣០ នាទី ខ្លួនកំពុងមើលគេរាំវង់នៅក្នុងភូមិបឹងក្រចាប់ខាងជើង ឃុំព្រែកតាមាក់ ស្រាប់តែមានមនុស្សមកប្រាប់ខ្លួនថា ឈ្មោះ យ សរ ដឹកគោរបស់ខ្លួនចេញពីផ្ទះ ហើយពេលនោះខ្លួនរត់មកដល់ផ្ទះ ក៏គោនៅចងកន្លែងដដែល បន្ទាប់មកខ្លួនក៏បានសួរឈ្មោះ [redacted] សុន ពីបញ្ហានេះ ឈ្មោះ [redacted] សុន បាននិយាយថា អម្បាញ់មិញឈ្មោះ យ សរ បានដឹកគោខ្លួនចេញតាមក្រោយផ្ទះរបស់វា ហើយគាត់បានឃើញរួចក៏និយាយឱ្យឈ្មោះ យ សរ ដឹកគោយកមកចងកន្លែងដដែលវិញ ពេលនោះឈ្មោះ យ សរ ក៏ធ្វើតាម រួចហើយក៏រត់គេចខ្លួនបាត់ទៅ ។ លុះព្រឹកឡើងថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៩៥ វេលាម៉ោង ៨:៣០នាទី ខ្លួនបានមកប្តឹងមេឃុំព្រែកតាមាក់ពីបញ្ហានេះ ។

តាមការអានចម្លើយរបស់ឈ្មោះ ឡ ម៉ល ដែលបានឆ្លើយនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ចំពោះមុខនគរបាលស្រុកខ្សាច់កណ្តាលថា : កាលពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥ ខ្លួនបានយកគោចងក្រោមផ្ទះដូចរាល់ថ្ងៃ (គោឈ្មោលពីរក្បាល មួយក្បាលសំបុរ-ស មួយក្បាលទៀតសំបុរចំប៉ា) ។ លុះព្រឹកឡើងខ្លួនក៏បាត់



Scanned with CamScanner

គោមួយក្បាលសំបុរ(ស)ស្នែងវែងទៅក្រោយពេលនោះខ្លួនមើលតាមដានជើង ឃើញដានដឹកចេញទៅក្រោយផ្ទះទិសខាងកើត ហើយខ្លួនក៏ចាត់មនុស្សឱ្យជួយដើររកគ្រប់ច្រកល្ហក តែរកមិនឃើញខ្លួនក៏ទៅប្តឹងនៅសាលាឃុំ នៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៥ ។ ដល់ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៥ កូនខ្លួនបានឃើញតាដោកគោរបស់ខ្លួនកប់នៅកំទេចសំរាមក្រោយផ្ទះ ។ នៅមុនដែលខ្លួនបាត់គោនោះ មានមនុស្សមិនស្គាល់ជាច្រើននាក់ដើរទិញគោ និង ឈ្មោះ យ សរ បានទៅលួចគោរបស់[redacted]សុខុម ម្តងដែរ តែម្ចាស់គេមកទាន់យកគោបានមកវិញ ហើយឈ្មោះ យ សរ ក៏រត់ គេចខ្លួនបាត់ទៅ ។

តាមការអានលិខិតសំណូមពររបស់ឈ្មោះ ឡ ម៉ល ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩៥ ថា : ខ្លួនសុំឱ្យឈ្មោះ យ សរ សងលុយថ្លៃគោរបស់ខ្លួនវិញចំនួន ០៧ជីមាស ( ប្រាំពីរជីមាស) ព្រោះឈ្មោះ យ សរ បានលួចគោរបស់ខ្លួន កាលពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥ និងសុំឱ្យតុលាការផ្តន្ទាទោសឈ្មោះ យ សរ តាមច្បាប់ ។

តាមការអានចម្លើយរបស់ឈ្មោះ អ ច ដែលបានឆ្លើយកាលពីថ្ងៃ ១៨ ខែ កក្កដា ឆ្នាំ១៩៩៥ នៅចំពោះមុខចៅក្រមស៊ើបអង្កេតថា ខ្លួនដើររកស៊ី ទិញលក់គោរួមផ្សំនឹងធ្វើស្រែចំការ ។ ចំពោះគោដែលទិញនោះ គឺគេដឹកយកមកដល់ផ្ទះ ។ ខ្លួនទើបតែស្គាល់ឈ្មោះ យ សរ បានប្រហែលពីរខែទេ ហើយក៏មិនដែលទិញគោពីឈ្មោះនេះដែរ ។

តាមការអានចម្លើយរបស់ឈ្មោះ អ ច ដែលបានឆ្លើយកាលពីថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៥ នៅចំពោះនគរបាលស្រុកខ្សាច់កណ្តាលថា : ខ្លួនដើរទិញគោតាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ គឺយកទៅលក់នៅជ្រោយចង្វារ ពេលនោះរកស៊ីជាមួយឈ្មោះ ញ នៅឃុំព្រែកលួង ។ ក្រោយមកដើរទិញគោជាមួយឈ្មោះ រ នៅភូមិព្រែកដូវហែម ឃុំព្រែកអំពិល ។ ក្រោយមកទៀតឈ្មោះ រ ក៏ឈប់នៅសល់តែខ្លួនដើរទិញគោជាមួយប្រពន្ធរហូតដល់សព្វថ្ងៃនេះ ។ ពេលទិញគោបាន ខ្លួនបានពឹងឱ្យគេបរឱ្យផង និងបរខ្លួនឯងផង ដូចជាទិញគោបាននៅភូមិវិហារសួគ៌ ខ្លួនឱ្យឈ្មោះពេញនៅភូមិវិហារសួគ៌ ឃុំវិហារសួគ៌ជាអ្នកបរឱ្យ ។ នៅភូមិព្រះប្រសប់ ឃុំព្រែកតាមាក់ ពេលទិញបានពឹងឱ្យឈ្មោះ ឆឺន, ញ៉ឹក, យ, នៅភូមិបឹងក្រចាប់ ឃុំព្រែកតាមាក់ជាអ្នកបរឱ្យ ជួនកាលបរមកត្រឹមផ្ទះរបស់ខ្លួន ជួនកាលបររហូតដល់កំពង់ដ ស្វាយជ្រំតែម្តង ។ ពេលទិញគោបាននៅភូមិពុកឬស្សីពឹងឱ្យឈ្មោះ ចន្ថា, អាច, ឈឿន, ស្រឿន នៅភូមិពុកឬស្សីបរឱ្យ ។ នៅភូមិព្រែកអំពិល ឃុំព្រែកលួង ឃុំព្រែកតាកូវ ឃុំស្វាយជ្រំ ពេលទិញបានបរខ្លួនឯង ។ ខ្លួនបាន ស្គាល់ឈ្មោះ យ នេះប្រហែលពីរឆ្នាំមកហើយ ដោយឈ្មោះ យ នេះទៅលេងផ្ទះឈ្មោះ ឆឺន ហើយឈ្មោះ ឆឺន ក៏ឱ្យឈ្មោះ យ នេះបរគោឱ្យខ្លួនតែម្តង តាំងពីពេលនោះមកឈ្មោះ យ ទើបតែបរគោឱ្យខ្លួនទើបតែបានពីរដងប៉ុណ្ណោះ ។ ខ្លួនមិនដែលជួបទំនាក់ទំនងជាមួយឈ្មោះ យ នេះនៅក្រៅពីផ្ទះឈ្មោះ ឆឺន ឡើយ ។ ពេលប្រហែលមួយខែនេះ ខ្ញុំមិនដែលជួបឈ្មោះ យ នេះទេ ។

តាមការអានចម្លើយរបស់ឈ្មោះ[redacted] សេន ដែលបានឆ្លើយកាលពីថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ នៅចំពោះមុខនគរបាលស្រុកខ្សាច់កណ្តាលថា មុនពេលដែលឈ្មោះ យ នេះ លួចគោទាំងពីរលើក គឺខ្លួនឃើញឈ្មោះ ច ជាដង្វៅគោនៅភូមិព្រែកដូវហែម ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មកទិញគោនៅភូមិបឹងក្រចាប់ជើង-ត្បូង ដោយជិះម៉ូតូគុបជ្រុងពណ៌ទឹកសមុទ្រជាមួយប្រពន្ធ។ ពេលឈ្មោះ ច ទិញគោបានគាត់ច្រើនទំនាក់ទំនងជាមួយឈ្មោះ [redacted] ឆឺន ដើម្បីឱ្យឈ្មោះ [redacted] ឆឺន នេះធានានូវប្រាក់ជំពាក់ដែលមិនទាន់ឱ្យគ្រប់តាមតំលៃគោ ។ ហើយឈ្មោះ ច នេះក៏ដឹកគោទៅឱ្យឈ្មោះ យ ឬឈ្មោះ[redacted] ញ៉ឹក ជាអ្នកបរគោទៅផ្ទះរបស់គាត់ ។ ខ្លួនឃើញឈ្មោះ យ បរគោដែលឈ្មោះ ច ទិញបានជាច្រើនលើក ។ តាំងពីគោរបស់ឈ្មោះ ឡ ម៉ល បាត់មក



Scanned with CamScanner

ឈ្មោះ ច មិនដែលឃើញមកទិញគោនៅភូមិបឹងក្រចាប់ជើង-ត្បូងទៀតទេ ។ ទើបតែនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ បានឃើញឈ្មោះ ច និងប្រពន្ធជិះម៉ូតូទៅវិហាសួគ៌តែមិនដឹងទៅរកអ្វីទេ ។

តាមការអានចម្លើយរបស់ឈ្មោះ [redacted] ដែលបានឆ្លើយកាលពីថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ នៅចំពោះនគរបាលស្រុកខ្សាច់កណ្ដាលថា : នៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៩៥ វេលាម៉ោង ១១:១៥នាទីយប់ ខ្លួនអង្គុយលើគ្រែបានបន្តិចក៏ចុះទៅដេកលើអង្រឹងបានមួយសន្ទុះ ស្រាប់តែឃើញឈ្មោះ យ សរ នៅភូមិបឹងក្រចាប់ជើង ឃុំព្រែកតាមាក់ ចូលមកស្រាយគោញីមួយក្បាល សំបុរ(ស)ស្ទែងលេច ជាគោរបស់ឈ្មោះ ខ នៅភូមិជាមួយគ្នា ឃើញដូច្នេះខ្លួនក៏ក្រោកពីលើអង្រឹងស្ទុះដើរតាមក្រោយ ហើយស្រែកថាអា យ អ្ហែងបរគោទៅណា អ្ហែងបរគោទៅចងឱ្យគេវិញ ពេលនោះឈ្មោះ យ បានបរត្រឡប់ចងឱ្យម្ចាស់គេវិញ ហើយក៏រត់គេចខ្លួនមួយរំពេច បន្ទាប់មកមនុស្សក៏ផ្អើលឆោឡោឡើង ។ ចំណែកឈ្មោះ យ រត់គេចខ្លួនរហូត លុះដល់ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៥ វេលាម៉ោង ១២:៣០នាទីយប់ ទើបសមត្ថកិច្ចតាមចាប់ខ្លួន ហើយបញ្ជូនមកអធិការនគរបាលស្រុកខ្សាច់កណ្ដាល ។

## តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានទោសលើជនជាប់ចោទ :

-ជនជាប់ចោទឈ្មោះ យ សរ ហៅ "យ" ជានីតិជនពិតប្រាកដ

-ចំពោះឈ្មោះ ច ដែលអយ្យការសម្រេចបង្គង់បណ្ដឹងអាជ្ញានោះ គឺជាឈ្មោះ ច ដែលចៅក្រមស៊ើបអង្កេតបានសួរចម្លើយរួចម្ដងហើយ ដូច្នេះតំណាងអយ្យការយល់ឃើញថា គ្មានពិរុទ្ធភាពលើឈ្មោះ ច នេះពីបទចោរកម្មនោះទេ ហេតុដូច្នេះសម្រេចលើកលែងការចោទប្រកាន់លើឈ្មោះ អ ច ។

-អំពើរបស់ជនជាប់ចោទពិតជាប៉ះពាល់ដល់នីត្យានុកូលភាពសង្គមទោះបីជនជាប់ចោទឆ្លើយបំវាងភស្ដុតាងក៏ដោយ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ យ សរ ពីបទចោរកម្ម ប្រព្រឹត្តនៅភូមិក្រចាប់ជើង ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥ តាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

## អ្នកការពារសិទ្ធិជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានដូចតទៅ :

កូនក្ដីរបស់ខ្លួនពិតជាបានប្រព្រឹត្តអំពើចោរកម្មប្រាកដមែន ប៉ុន្តែ :

-ជនជាប់ចោទជាក្មេងកំព្រាខ្វះការអប់រំឱ្យបានដិតដល់ ឆាប់ជឿតាមពាក្យសំដីរបស់គេ ។

- ជនជាប់ចោទមានករិតវប្បធម៌ទាប ដោយបានរៀនត្រឹមថ្នាក់ទី ៣ ប៉ុណ្ណោះ និងករិតជីវភាពក្រលំបាក ។

អាស្រ័យហេតុនេះសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យកូនក្ដីរបស់ខ្លួនផង ។

តុលាការឱ្យជនជាប់ចោទនិយាយសំដីចុងក្រោយ : ខ្លួនគ្មានពាក្យអ្វីនិយាយទៀតទេ ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់សាក្សីរបំភ្លឺ

-ក្រោយបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់អ្នកការពារ

-ក្រោយពីបានស្ដាប់ចម្លើយចុងក្រោយរបស់ជនជាប់ចោទ



Scanned with CamScanner

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

**យល់ឃើញថា**

-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ ដែលបានលុបចោលបណ្ដឹងអជ្ញាលើឈ្មោះ ច មានលក្ខណៈត្រឹមត្រូវទៅតាមច្បាប់ ដោយហេតុថាឆ្លងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ យ សរ បានបង្ហាញថា ជនឈ្មោះ ច មិនពាក់ព័ន្ធក្នុងបទល្មើសចោរកម្មនេះទេ ដូចនេះ តុលាការ និងពុំលើកយកករណីឈ្មោះ ច មកពិចារណាឡើយ ។

-ជនជាប់ចោទឈ្មោះ យ សរ បានសារភាពថា ៈខ្លួនពិតជាបានទៅដឹកយកគោរបស់ឈ្មោះ ឡ ម៉ល ដែលបានចងនៅក្រោមផ្ទះនៅវេលាអាធ្រាត នៃថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥ ប្រាកដមែន ។

-មានសំអាងច្បាស់លាស់បញ្ជាក់ថា ជនជាប់ចោទឈ្មោះ យ សរ ពិតជាបានដឹងច្បាស់ថា គោឈ្មោល ដែលខ្លួនបានដឹកយកជាកម្មសិទ្ធិរបស់ឈ្មោះ ឡ ម៉ល ។

-ការចូលទៅស្រាយយកគោ និងដឹកគោរបស់អ្នកដទៃ នៅវេលាយប់អាធ្រាតដោយពុំឱ្យម្ចាស់ដឹង បង្ហាញពីចេតនាទុច្ចរិតចង់បានទ្រព្យអ្នកដទៃ ដើម្បីជាប្រយោជន៍ខ្លួន ។

-ទោះបីជាជនជាប់ចោទបានឆ្លើយថា គោដែលខ្លួនដឹកយកត្រូវជនមិនស្គាល់មុខបានវ៉ាយខ្លួន ហើយស្គាល់យកគោទៅបាត់ក្ដី ក៏អំពើរបស់ជននេះត្រូវចាត់ទុកថា បានប្រព្រឹត្តល្មើសដល់ទីបញ្ចប់រួចហើយ ហើយត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ។

-ជនជាប់ចោទឈ្មោះ យ សរ ហៅ "យ " ជនសមត្ថជនដែលមានស្មារតីធម្មតាអាចយល់ដឹងអំពីអំពើរបស់ខ្លួន និងបច្ច័យដែលកើតឡើងអំពីអំពើនោះ ។

-មានសំអាងគ្រប់គ្រាន់បញ្ជាក់ថា ឈ្មោះ ឡ ម៉ល ពិតជាបានបាត់គោមួយក្បាលសបុរ(ស)ស្នែងផាង កំពស់ ១.៤៥ម៉ែត្រ កាលពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥ ។

-អំពើរបស់ជនជាប់ចោទឈ្មោះ យ សរ បានរំលោភលើកម្មសិទ្ធិស្របច្បាប់របស់ពលរដ្ឋ និងជាអំពើដែលច្បាប់ព្រហ្មទណ្ឌបានហាមឃាត់ ។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទឈ្មោះ យ សរ ពិតជាបានប្រព្រឹត្តបទចោរកម្ម នៅចំណុចភូមិបឹងក្រចាប់ជើង ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥ ។

-បទល្មើសដែលមានចែង និងបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-មាត្រា ៤៣ បានចែងថា គ្រប់ជនដែលលួច ឬ ប៉ុនប៉ងលួចទ្រព្យសម្បត្តិ រូបវន្តបុគ្គល ឬនីតិបុគ្គល ដោយពុំមានស្ថានទម្ងន់ទោស ដូចមានចែងក្នុងមាត្រា ៣៤ ត្រូវមានទោសពីបទលួច ហើយត្រូវផ្ដន្ទាទោសដាក់គុកពី ០៦ខែ ដល់ ០៥ឆ្នាំ ។

-ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី បានទាមទារសំណងក្នុងលិខិតចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩៥ ជាមាស ០៧ជីមាស ដែលតុលាការនឹងលើកយកមកពិចារណា និងសម្រេចសេចក្ដីឱ្យបានសមស្របតាមព្យសនកម្ម ។

-តម្លៃគោដែលដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងមានលក្ខណៈសមស្របនឹងតម្លៃគោជាក់ស្ដែង នៃគោប្រើ



Scanned with CamScanner

ដែលមានកំពស់ ១.៨៥ម៉ែត្រ ។

-មាសលើទីផ្សារសេរីនាថ្ងៃទី ១១ ខែ មករា ឆ្នាំ១៩៩៦ មានតម្លៃជាមធ្យមមួយជីស្មើនឹង ១០០.០០០រៀល (ដប់ម៉ឺនរៀល ។)

-សេចក្តីសន្និដ្ឋានរបស់អ្នកការពារមានលក្ខណៈសមហេតុផល លើចំណុចតូចមួយស្តីពីជីវភាព និងកិរិតវប្បធម៌របស់ជនជាប់ចោទ ។

-ជនជាប់ចោទឈ្មោះ ឃ សរ ហៅ " ឃ " ត្រូវឃុំខ្លួនកាលពីថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

## ហេតុដូចនេះសំរេច

១-ផ្តន្ទាទោស :

ផ្តន្ទាទោសឈ្មោះ ឃ សរ ហៅ " ឃ " កើតឆ្នាំ ១៩៦៧ កំណត់ដាក់ពន្ធនាគារ ០១ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ១៩៩៥ ពីបទ ចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិក្រចាប់ជើង ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីយប់ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥ ។ បទល្មើសដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

២-អោយឈ្មោះ ឃ សរ សងសំណងជួសជុលការអន្តរាយទៅជនរងគ្រោះ ឡ ម៉ល ជាប្រាក់ចំនួន ៧០០.០០០រៀល (ចិតសិបម៉ឺនរៀល) នៅពេលសាលក្រមស្ថាពរ ។ ករណីឈ្មោះ ឃ សរ គ្មានទ្រព្យសងធនទណ្ឌគ្រប់ចំនួនទេត្រូវដាក់គុកបង្ខំលើរូបកាយដើម្បីទារប្រាក់ធនទណ្ឌ ។

ត្រូវដាក់គុកបង្ខំលើរូបកាយចំនួន :

-២០០ថ្ងៃ សម្រាប់ប្រាក់ ១០០.០០០រៀល

-៦០០ថ្ងៃ សម្រាប់ប្រាក់ ៦០០.០០០រៀល

សរុបចំនួន ៨០០ថ្ងៃ តែមិនឱ្យឈ្មោះនេះរងទោសគុកបង្ខំលើរូបកាយលើពី ០២ឆ្នាំឡើយ ។ តាមបញ្ញត្តិមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយ ក្នុងរឿងព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ១៨ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

៣-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

[redacted]

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីអនុវត្តសាលឱ្យសម្រេចតាមសាលក្រមនេះ និង ឱ្យអាជ្ញាធរគ្រប់តំណែងគ្រប់ជាន់ថ្នាក់ ជួយផ្តល់កំលាំងដើម្បីសម្រេចការអនុវត្តនេះ បើមានសំណូមពរត្រឹមត្រូវតាមផ្លូវច្បាប់ ។

*កណ្តាល, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៦*

**ប្រធានតុលាការខេត្តកណ្តាល** | **ក្រឡាបញ្ជី**

[redacted] | [redacted]



Scanned with CamScanner